រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# ក្របខ័ណ្ឌគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ សម្រាប់គាំទ្រការអនុវត្ត កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ខែវិច្ឆិកា ឆ្នាំ២០១៦

# មាតិកា

២.១. សេចក្តីផ្តើម

២.២. យុទ្ធសាស្រ្តចតុកោណ

២.៣. ក្របខ័ណ្ឌយុទ្ធសាស្រ្តស្តីពីកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ

២.៤. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

២.៥. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

# ២.១ សេចក្តីផ្តើម

- កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជាត្រូវបានផ្តួចផ្តើម និងយកចិត្តទុកដាក់ ក្រោយការបោះឆ្នោតសកលឆ្នាំ១៩៩៣
- នៅឆ្នាំ២០០២ វិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់បានចាប់ផ្តើម
- តាមរយៈបទពិសោធន៍ និងសមិទ្ធផលដ៏ជោគជ័យនៃការអនុវត្ត កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ ឃុំ សង្កាត់ រាជរដ្ឋាភិបាលកម្ពុជាមានឆន្ទៈនិងការតាំងចិត្តក្នុងការពង្រឹងពង្រីកកំណែទម្រង់នេះ។

## ២.១ សេចក្តីផ្តើម (ត)

- ក្របខ័ណ្ឌគោលនយោបាយ និងក្របខ័ណ្ឌច្បាប់៖
  1. យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ទី២ និងទី៣
  2. ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
  3. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
  4. ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
  5. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
  6. ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។

# ២.១ សេចក្តីផ្តើម (ត)

## ក្របខ័ណ្ឌពេលវេលានៃដំណើរការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា



# ២.២ យុទ្ធសាស្ត្រចតុកោណ

- អភិបាលកិច្ចល្អ ត្រូវបានចាត់ទុកជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី១ ដំណាក់កាលទី២ និងដំណាក់កាលទី៣
- ដើម្បីសម្រេចបាននូវគោលដៅនៃអភិបាលកិច្ចល្អនេះ រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតការយកចិត្តទុកដាក់ធ្វើកំណែទម្រង់លើវិស័យចំនួន៤ រួមមាន៖
  - ការប្រយុទ្ធប្រឆាំង នឹងអំពើពុករលួយ
  - កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
  - កំណែទម្រង់រដ្ឋបាលសាធារណៈ និង
  - កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ។

## ២.៣ ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ (D&D)

- អនុម័តក្នុងឆ្នាំ២០០៥
- ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ មានគោលបំណងកំណត់អំពី៖
  - ចក្ខុវិស័យពាក់ព័ន្ធកំណែទម្រង់អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ
  - គោលដៅនៃយុទ្ធសាស្ត្រជាតិក្នុងកំណែទម្រង់D&D
  - វិសាលភាពនៃកំណែទម្រង់D&D
  - របៀបរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
  - ណែនាំដល់ការងារកំណែទម្រង់ទាំងអស់ ដែលមានផលប៉ះពាល់ដល់ប្រព័ន្ធគ្រប់គ្រងនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិ។

# ២.៤ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

## ក. ទិដ្ឋភាពទូទៅ

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ចែកជា១០ជំពូក និងមាន ៩០មាត្រា។

## ខ. ក្រុមប្រឹក្សាឃុំ សង្កាត់

- ការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់៖
  - លើកទី ១៖ ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០២
  - លើកទី ២៖ ថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៧ និង
  - លើកទី ៣៖ ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១២។

# ២.៤ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (ត)

## ខ. ក្រុមប្រឹក្សាឃុំ សង្កាត់

- ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកពី០៥រូប ទៅ១១រូប ផ្អែកតាមកត្តាប្រជាសាស្ត្រ និងភូមិសាស្ត្ររបស់ខ្លួន។
- ប្រធានក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ គឺជាមេឃុំ ចៅសង្កាត់។
- មេឃុំ ចៅសង្កាត់ជាអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រង និងចាត់ចែងនូវរាល់កិច្ចការនានានៅរដ្ឋបាលឃុំ សង្កាត់។
- មេឃុំ ចៅសង្កាត់ មានជំនួយការពីររូបគឺ ជំទប់ទី១ និងចៅសង្កាត់រងទី១ និងជំទប់ទី២ និងចៅសង្កាត់ទី២។
- មានគណៈកម្មាធិការមួយចំនួនតាមការចាំបាច់ អាស្រ័យតាមការកំណត់ដោយច្បាប់ និងតម្រូវការរបស់មូលដ្ឋានផ្ទាល់។

# ២.៤ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (ត)

*រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់*



# ២.៤ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (ត)

## គ. តួនាទី និងមុខងារនៃរដ្ឋបាលឃុំ សង្កាត់

- ជានារក្សាសន្តិសុខសណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ
  - រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់
  - លើកកម្ពស់ផាសុខភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ
  - ជំរុញកិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច សំដៅលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
  - ការពារថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ

# ២.៤ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (ត)

## គ. តួនាទី និងមុខងារនៃរដ្ឋបាលឃុំ សង្កាត់

- ជាភ្នាក់ងារតំណាងក្រសួង ស្ថាប័នថ្នាក់ជាតិក្នុងការអនុវត្តមុខងារមួយចំនួនដែលទទួលបានការផ្ទេរពីរាជរដ្ឋាភិបាល និង/ឬក្រសួងស្ថាប័នថ្នាក់ជាតិ។
  - ឧទាហរណ៍៖ ការចុះបញ្ជីអត្រានុកូលដ្ឋាន និងការចុះឈ្មោះអ្នកបោះឆ្នោតនៅក្នុងឃុំ សង្កាត់។ល។

# ២.៤ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (ត)

## ឃ. ព្រំដែនអំណាចនៃរដ្ឋបាលឃុំ សង្កាត់

- ស្វ័យភាពក្នុងការគ្រប់គ្រង និងចាត់ចែងកិច្ចការនានានៅមូលដ្ឋានរបស់ខ្លួន
- រដ្ឋបាលឃុំ សង្កាត់មិនអាចធ្វើសកម្មភាពណាមួយដែលផ្ទុយនឹងគោលការណ៍ និងបទប្បញ្ញត្តិដែលបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាននានាឡើយ។

# ២.៤ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (ត)

## ឃ. ព្រំដែនអំណាចនៃរដ្ឋបាលឃុំ សង្កាត់

➢ រដ្ឋបាលឃុំ សង្កាត់មិនអាចធ្វើសេចក្តីសម្រេចលើវិស័យដូចខាងក្រោម៖

- ព្រៃឈើ
- ប្រៃសណីយ៍ និងទូរគមនាគមន៍
- ការពារជាតិ
- សន្តិសុខជាតិ
- រូបិយវត្ថុ
- នយោបាយក្រៅប្រទេស
- គោលនយោបាយសារពើពន្ធ និង
- វិស័យផ្សេងទៀតដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ

# ២.៤ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (ត)

## ង.ប្រព័ន្ធកសាងផែនការឃុំ សង្កាត់

- ត្រូវប្រើប្រាស់ជាមូលដ្ឋានសម្រាប់ណែនាំរាល់ការសម្រេចចិត្តក្នុងការងារអភិវឌ្ឍន៍ឃុំ សង្កាត់ និងសម្រាប់កសាងកម្មវិធីវិនិយោគ និងការរៀបចំថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់
- ត្រូវអនុម័តដោយក្រុមប្រឹក្សាឃុំ សង្កាត់នៅឆ្នាំទី១នៃអាណត្តិរបស់ខ្លួន
- មានសុពលភាពរយៈពេល០៥ឆ្នាំ ហើយត្រូវពិនិត្យឡើងវិញជារៀងរាល់ឆ្នាំតាមរយៈការរៀបចំកម្មវិធីវិនិយោគ និងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់

# ២.៤ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (ត)

## ង.ប្រព័ន្ធកសាងផែនការឃុំ សង្កាត់ (ត)

- ត្រូវឱ្យស្របទៅនឹងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចរបស់ជាតិ
- ត្រូវរៀបចំជាលាយលក្ខណ៍អក្សរ ដោយមានផែនទី ស្ថិតិ និងឯកសារពាក់ព័ន្ធផ្សេងៗភ្ជាប់ជាមួយ
- ត្រូវធានាឱ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ
- បន្ទាប់ពីអនុម័តជាឯកសារផ្លូវការ ត្រូវធ្វើការផ្សព្វផ្សាយ។

# ២.៤ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (ត)

ច. ប្រភពចំណូលឃុំ សង្កាត់



# ២.៥ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## ក. ទិដ្ឋភាពទូទៅ

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចែកជា០៨ជំពូក និងមាន២៨៦មាត្រា។
- កំណត់អំពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវធ្វើឡើងតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។
- ការបង្កើតរដ្ឋបាលឯកភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

# ២.៥ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ត)

## ខ. ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

- ចំនួនសមាជិកនៃក្រុមប្រឹក្សានីមួយៗត្រូវកំណត់ដោយផ្អែកតាមកត្តាប្រជាសាស្ត្រ និងកត្តាភូមិសាស្ត្រដូចខាងក្រោម ៖
  - ក្រុមប្រឹក្សារាជធានីភ្នំពេញ មានសមាជិកមិនលើសពី២១រូប
  - ក្រុមប្រឹក្សាខេត្ត មានសមាជិកពី០៩-២១រូប
  - ក្រុមប្រឹក្សាក្រុង មានសមាជិកពី០៧-១៥រូប
  - ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ មានសមាជិកពី០៧-១៥រូប។

# ២.៥ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ត)

## រចនាសម្ព័ន្ធរដ្ឋបាលរាជធានី ខេត្ត



# ២.៥ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ត)

## រចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក



# ២.៥ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ត)

## ឃ. តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា

- មានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងខាងប្រតិបត្តិ
- ការប្រើប្រាស់សិទ្ធិអំណាចខាងបញ្ញត្តិត្រូវធ្វើឡើងតាមរយៈការចេញដីកា
- ចំពោះសិទ្ធិអំណាចខាងប្រតិបត្តិ ត្រូវធ្វើឡើងតាមរយៈការធ្វើសេចក្តីសម្រេចនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។
- បំពេញការងាររបស់ខ្លួនតាមរយៈការធ្វើសេចក្តីសម្រេចនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។

# ២.៥ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ត)

## ឃ. តួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា

➢ ក្រុមប្រឹក្សាត្រូវធ្វើសេចក្តីសម្រេច ឬដីកាតាមការចាំបាច់ទាក់ទិនទៅនឹង៖

- ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មី
- មុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សា
- មុខងារជាជម្រើសរបស់ក្រុមប្រឹក្សា
- គម្រោងថវិកាប្រចាំឆ្នាំ និងក្របខណ្ឌចំណាយរយៈពេលមធ្យម
- បញ្ហាហិរញ្ញវត្ថុផ្សេងទៀត
- ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ
- និងការងារផ្សេងៗមួយចំនួនទៀត

# ២.៥ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ត)

## ង. អំពីគណៈអភិបាល

### ១.ការតែងតាំង

### លក្ខណៈសម្បត្តិក្នុងការតែងតាំង

| មុខតំណែង | ឋានន្តរស័ក្តិ | អាយុ អប្បបរមា(ឆ្នាំ) | បទពិសោធន៍ការងារ(ឆ្នាំ) | សញ្ញាបត្រ |
|---|---|---|---|---|
| អភិបាល រាជធានី ខេត្ត | ឧត្តមមន្ត្រី | ៣៥ | ០៧ | បរិញ្ញាបត្រ |
| អភិបាលរង រាជធានី ខេត្ត | វរមន្ត្រី | ៣៥ | ០៥ | បរិញ្ញាបត្រ |
| អភិបាល ក្រុង ស្រុក ខណ្ឌ | អនុមន្ត្រី | ៣០ | ០៥ | បរិញ្ញាបត្រ |
| អភិបាលរង ក្រុង ស្រុក ខណ្ឌ | នាយក្រមការ | ២៥ | ០៣ | បរិញ្ញាបត្ររង |

# ២.៥ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ត)

## ង. អំពីគណៈអភិបាល (ត)

### ១.ការតែងតាំង (ត)

❖ចំនួននៃគណៈអភិបាលសម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានកំណត់ដូចខាងក្រោម៖

- គណៈអភិបាលរាជធានីភ្នំពេញ មានចំនួនយ៉ាងច្រើន០៧រូប
- គណៈអភិបាលខេត្ត មានចំនួនពី ០៣រូប ទៅ ០៧រូប
- គណៈអភិបាលក្រុង ស្រុក ខណ្ឌ មានចំនួនពី ០៣រូប ទៅ ០៥រូប។

# ២.៥ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ត)

## ង. អំពីគណៈអភិបាល (ត)

### ១.<u>ការតែងតាំង</u> (ត)

❖ ការតែងតាំងអភិបាល អភិបាលរងត្រូវធ្វើឡើងដូចខាងក្រោម៖

- អភិបាលរាជធានី និងអភិបាលខេត្ត ត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី តាមសេចក្ដីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- អភិបាលរងរាជធានី អភិបាលរងខេត្ត អភិបាលក្រុង អភិបាលស្រុក និងអភិបាលខណ្ឌ ត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- អភិបាលរងក្រុង អភិបាលរងស្រុក និងអភិបាលរងខណ្ឌ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

# ២.៥ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ត)

## ង. អំពីគណៈអភិបាល (ត)

### ២. តួនាទី និងភារកិច្ចរបស់គណៈអភិបាល

- ផ្តល់យោបល់ជូនក្រុមប្រឹក្សា
- គ្រប់គ្រង និងចាត់ចែងអនុវត្តរាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សា
- ធ្វើការស៊ើបអង្កេតជាបន្ទាន់ នៅពេលទទួលរបាយការណ៍ ឬព័ត៌មានអំពីការរំលោភអំណាចនៅក្នុងដែនសមត្ថកិច្ច
- អភិបាលក៏មានតួនាទីជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលក្នុងដែនសមត្ថកិច្ច។

# ២.៥ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ត)

### ច. ទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាល

- គណៈអភិបាល គឺជាអ្នកអនុវត្តរាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សា
- ក្រុមប្រឹក្សាតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ
- គណៈអភិបាលត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា
- អភិបាលរាយការណ៍អំពីសកម្មភាពក្នុងនាមតំណាងថ្នាក់ជាតិ
- ក្រុមប្រឹក្សាអាចស្នើអភិបាលរាយការណ៍អំពីកិច្ចការពិសេសណាមួយដែលប៉ះពាល់ដល់ផលប្រយោជន៍របស់ប្រជាពលរដ្ឋ
- ក្រុមប្រឹក្សាអាចផ្តល់អនុសាសន៍ និងណែនាំដល់អភិបាលអំពីការអនុវត្តតួនាទីក្នុងនាមតំណាងថ្នាក់ជាតិ។

# ២.៥ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ត)

## ឆ. ប្រព័ន្ធកសាងផែនការ

- ❖ត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍន៍5ឆ្នាំនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ
- ❖ផែនការអភិវឌ្ឍន៍នេះ ត្រូវរួមបញ្ចូលនូវខ្លឹមសារសំខាន់ៗដូចជា៖
  - ចក្ខុវិស័យរបស់ក្រុមប្រឹក្សា
  - ការប៉ាន់ប្រមាណពីកម្រិតនៃការអភិវឌ្ឍដែលមានស្រាប់ និងតម្រូវការអភិវឌ្ឍន៍
  - ផែនការគ្រប់គ្រងមហន្តរាយ
  - ផែនការហិរញ្ញវត្ថុ
  - យុទ្ធសាស្ត្រអនុវត្តផែនការអភិវឌ្ឍន៍ ដើម្បីធានាតម្លាភាព និងគណនេយ្យចំពោះប្រជាពលរដ្ឋ

# ២.៥ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ត)

ជ. ប្រភពថវិការបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- **ចំណូលផ្ទាល់៖**
  - ចំណូលសារពើពន្ធ
  - ចំណូលមិនមែនសារពើពន្ធ
- **ចំណូលចែករំលែក៖** បានមកពីការផ្ទេរពីថ្នាក់ជាតិ និងពីការអនុវត្តមុខងារជាភ្នាក់ងារ
- **ចំណូលពីប្រភពផ្សេងទៀត៖** ការចូលរួមចំណែករបស់ប្រជាពលរដ្ឋមូលដ្ឋាន និងពីអង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ ឬកម្មវិធីនានាជាដើម។

# សូមអរគុណ!